ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីភ្នាក់ងារបញ្ជាក់ចំណាយ
សេវាសុខាភិបាល

លេខ.១០២៤/.....ទ.ប.ច.ស.

ថ្ងៃសុក្រ ៤ កើត ខែ ចេត្រ ឆ្នាំរកា ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២៤

សេចក្តីជូនដំណឹង

ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល សូមជូនដំណឹងអ្នកខ្សែទីឌីអូជំនួយទាក់ទងនឹងតម្រូវការឯកសារចាំបាច់ដើម្បីស្នើសុំទូទាត់ជាមួយគម្រោងមូលនិធិសមធម៌សុខាភិបាល និងការបំពេញឯកសារស្នើសុំថវិកាបុរេប្រទាន

ក្នុងការអនុវត្តជាមួយគម្រោងមូលនិធិសមធម៌សុខាភិបាលនាពេលកន្លង នៅតាមមូលដ្ឋានសុខាភិបាលគ្រប់កម្រិត គឺបានរៀបចំឯកសារគាំទ្រផ្សេងៗដើម្បីធ្វើការស្នើសុំទូទាត់ពីគម្រោងមូលនិធិសមធម៌មានទម្រង់ខុសៗគ្នា។ ដើម្បីជាជំនួយដល់មូលដ្ឋានសុខាភិបាល ក្នុងការរៀបចំទុកជាក់ឯកសារគាំទ្រផ្សេងៗក្នុងការស្នើសុំទូទាត់ពីគម្រោងមូលនិធិសមធម៌សុខាភិបាលឱ្យបានត្រឹមត្រូវ និងពេញលេញក្រុមការងារនៃទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលបានផលិតជាខ្សែវីឌីអូចំនួន៤ រួមមាន៖

រៀបបំពេញឧបសម្ព័ន្ធ១០ - ស្នើសុំថវិកាបុរេប្រទាន (**វីឌីអូទី១៖ Link**)

ឯកសារសម្រាប់ការស្នើសុំទូទាត់ពីគម្រោងមូលនិធិសមធម៌សុខាភិបាល៖

- នៅកម្រិតមណ្ឌលសុខភាព (**វីឌីអូទី២៖ Link**)
- នៅកម្រិតមណ្ឌលសុខភាពមានគ្រែ (**វីឌីអូទី៣៖ Link**)
- នៅកម្រិតមន្ទីរពេទ្យគ្រប់កម្រិត CPA1 CPA2 CP3 និង មន្ទីរពេទ្យឬមជ្ឈមណ្ឌលជាតិ (**វីឌីអូទី៤៖ Link**)

ដើម្បីចូលទៅមើលវីឌីអូជំនួយផ្សេងៗ សូមចុចទំព័រ "ជំនួយ" ដែលស្ថិតនៅខាងលើមីនុយនៃប្រព័ន្ធ PMRS។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរសុខាភិបាលរាជធានីខេត្ត ប្រធានមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែកខេត្ត មន្ទីរពេទ្យបង្អែកស្រុក ការិយាល័យស្រុកប្រតិបត្តិ អតីតពេទ្យស្រុក (មណ្ឌលសុខភាពមានគ្រែ) និងមណ្ឌលសុខភាព ទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ព័ត៌មានបន្ថែមសូមទាក់ទងជំនួយបច្ចេកទេស PMRS Hotline៖

- ១២៧៣ (ដោយឥតគិតថ្លៃ)
- (០៧១) ៤៤៤ ០០៤ | (០៩២) ៤៤៤ ០០៤ | (០៨៦) ៤៤៤ ០០៤
- Telegram: (០៨៦) ៤៤៤ ០០៤

PMRS
@PMRSCAMBODIA